# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ ០០១ ន.គ.ស ណ.ណ.ន.

ថ្ងៃព្រហស្បតិ៍ ១០រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២២

# សេចក្តីណែនាំ
## ស្តីពី
## ការដាក់លិខិតជូនដំណឹងសម្រាប់ការប្រើប្រាស់ភាសាអង់គ្លេស ក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬ ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មកនិយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបថា៖ ដើម្បីអនុវត្តសារាចរណែនាំលេខ ០០៩ សហវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ស្តីពី“**ការប្រើប្រាស់ភាសា និងរូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ**” របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **និយ័តករគណនេយ្យនិងសវនកម្ម** សូមធ្វើការណែនាំដូចខាងក្រោម៖

១. សហគ្រាសដែលបានចុះបញ្ជីផ្លូវការរួចហើយ ត្រូវធ្វើការជូនដំណឹងអំពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មកនិយ័តករគណនេយ្យនិងសវនកម្ម ចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ រហូតដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ជាកំហិត។ សម្រាប់សហគ្រាសដែលទើបបង្កើតថ្មី ត្រូវធ្វើការជូនដំណឹងអំពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រនិង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មកនិយ័តករគណនេយ្យនិងសវនកម្ម មិនឱ្យហួសរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលសហគ្រាសបានចុះបញ្ជីជាស្ថាពរជាមួយអគ្គនាយកដ្ឋានពន្ធដារ។

២. សហគ្រាសត្រូវប្រើប្រាស់ប្រព័ន្ធអនឡាញ (E-Filling System) របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនលិខិតជូនដំណឹងសម្រាប់ការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រនិង/ឬ ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធតាមគំរូលិខិតដែលបានផ្តល់ជូនក្នុងប្រព័ន្ធស្រាប់។

៣. សហគ្រាសត្រូវអនុវត្តតាមការណែនាំជាជំហានៗដូចខាងក្រោម ដើម្បីដាក់លិខិតជូនដំណឹងមក **ន.គ.ស.**៖

**ជំហានទី១៖** សហគ្រាសត្រូវបង្កើតគណនីនៅលើប្រព័ន្ធ E-Filling របស់ **ន.គ.ស.** ដើម្បីអាចប្រើប្រាស់មុខងារជូនដំណឹងនេះបាន (ប្រសិនបើសហគ្រាសរបស់លោកអ្នកធ្លាប់មានគណនីប្រើប្រាស់ប្រព័ន្ធ E-Filling របស់ **ន.គ.ស.** រួចហើយ សូមប្រើប្រាស់គណនីដែលមានស្រាប់)។

**ជំហានទី២៖** សហគ្រាសត្រូវបំពេញព័ត៌មានទូទៅជាមុនសិន (សម្រាប់សហគ្រាសដែលទើបបង្កើតគណនីថ្មីនៅលើប្រព័ន្ធ E-Filling) រួចរក្សាទុក។

**ជំហានទី៣៖** សូមចុចលើមុខងារ “ជូនដំណឹងអំពីការប្រើប្រាស់ភាសា” ដែលមាននៅលើប្រព័ន្ធ E-Filling របស់ **ន.គ.ស.** បន្ទាប់មកសូមបំពេញព័ត៌មានបន្ថែម និងទាញយកទម្រង់លិខិតជូនដំណឹង ដើម្បីបំពេញព័ត៌មានអំពីការប្រើប្រាស់ភាសា ដោយបញ្ជាក់ពីឈ្មោះប្រព័ន្ធ ឈ្មោះក្រុមហ៊ុននិងប្រទេសផលិត និងភាសាប្រើប្រាស់ក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រតាមគំរូលិខិតរបស់ **ន.គ.ស.** រួចសូមបញ្ជូនលិខិតនោះមកវិញតាមប្រព័ន្ធ E-Filling ជាការស្រេច។

សហគ្រាសត្រូវរក្សាទុកលិខិតជូនដំណឹងច្បាប់ដើមឱ្យបានត្រឹមត្រូវនៅទីតាំងសហគ្រាសរបស់ខ្លួន សម្រាប់ការត្រួតពិនិត្យអនុលោមភាពពី **ន.គ.ស.** នៅពេលក្រោយ។

សហគ្រាសណាដែលប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬក្នុងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត ដោយមិនបានដាក់លិខិតជូនដំណឹងមក និយ័តករគណនេយ្យនិងសវនកម្ម តាមពេលវេលាដូចបានកំណត់ខាងលើ នឹងត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យ លេខ៧៩ អនុក្រ.បក.ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាសទាំងអស់ មេត្តាជ្រាប និងអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ប៊ូ ចារិន**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម**
**សូមចូលរួមក្នុង Telegram Channel របស់**
**និយ័តករគណនេយ្យនិងសវនកម្ម**